# ដំណើរទៅកាន់ ដងវិថី

## សេរីភាពជួបប្រជុំ ដោយសន្តិវិធីនៅកម្ពុជា

AMNESTY INTERNATIONAL

# សេចក្តីសង្ខេប

“បន្ទាប់ពីពួកគេបានវាយខ្ញុំពីក្រោយ ខ្ញុំហាក់ដូចជាត្រីងាប់មួយក្បាលអញ្ចឹង។ ពួកគេចាប់ខ្ញុំឲ្យឈរនៅមួយកន្លែង ហើយពួកគេលោតមកទាត់ដើមទ្រូងយ៉ាងខ្លាំង។ ក្រោយមកពួកគេឈរព័ទ្ធជុំវិញខ្ញុំ ដើម្បីបាំងកុំឲ្យអ្នកសារព័ត៌មានថត។ ពួកគេឈរព័ទ្ធជារង្វង់ ដាក់ខ្ញុំនៅកណ្តាល ហើយក៏ដាល់ខ្ញុំ និងវាយខ្ញុំច្រើនណាស់។”

យ៉ុង សុខជា អាយុ ១៧ឆ្នាំ ជាកម្មកររោងចក្រកាត់ដេរ ត្រូវបានគេចាប់ខ្លួន ហើយវាយដំនៅផ្លូវវែងស្រែង រាជធានីភ្នំពេញ នៅថ្ងៃទី២ ខែមករា ឆ្នាំ២០១៤។[1]

នៅចុងឆ្នាំ២០១៣ បាតុកម្មជាបន្តបន្ទាប់ បានផ្ទុះឡើងនៅរាជនីភ្នំពេញរបស់ប្រទេសកម្ពុជា ហើយបានឈានដល់កម្រិតខ្ពស់បំផុតនៅចុងខែធ្នូ ក្នុងការតវ៉ាមហាជនច្រើនលើកលើលទ្ធផលបោះឆ្នោតជាតិដ៏ចម្រូងចម្រាស់ និងការអំពាវនាវតម្លើងប្រាក់ឈ្នួលអប្បបរមាដល់កម្មកររោងចក្រកាត់ដេរ[2]។ អ្នកគាំទ្រគណបក្សសង្គ្រោះជាតិជាច្រើន ដែលជាគណបក្សប្រឆាំងដ៏ធំមួយរបស់កម្ពុជា បានទៅជួបជុំជាមួយកម្មករជាច្រើនពាន់នាក់ដែលកំពុងតែធ្វើកូដកម្ម និងជាមួយក្រុមដែលមិនរងប៉ះពាល់ដទៃទៀត។ ប្រជាពលរដ្ឋជាច្រើនរយពាន់នាក់ ធ្វើដំណើរទៅកាន់ដងវិថីនៃរាជធានីភ្នំពេញ ដើម្បីទាមទារឲ្យមានការផ្លាស់ប្តូរស្ថានភាពទ្រឹងផ្នែកសេដ្ឋកិច្ច សង្គម និងនយោបាយរបស់ប្រទេសកម្ពុជា។

---

[1]សម្ភាសន៍ជាមួយ យ៉ុង សុខជា នៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៤

[2]ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ រដ្ឋាភិបាលបានប្រកាសថា ប្រាក់បៀវត្សន៍អប្បបរមារបស់កម្មករក្នុងវិស័យកាត់ដេរកម្ពុជា បានឡើងពី ៨0 ដុល្លារអាមេរិកទៅ ៩៥ ដុល្លារអាមេរិក ក្នុងខែមេសា ឆ្នាំ២០១៤ ហើយសហជីពបានអំពាវនាវឲ្យឡើងច្រើនជាងនេះ។ សូមមើលអត្ថបទ៖ អូន ភាព និងកូលីន ម៉ី "បៀវត្សន៍ប្រចាំខែកើនដល់ ៩៥ ដុល្លារ សហជីពប្តេជ្ញាធ្វើកូដកម្ម" ឃែមបូឌាឌេលី ចុះថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ២០១៤ និងអត្ថបទស្តីពី ម៉ុម គន្ធា "កូដកម្មហុយផ្សែង" ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៣។

នៅដើមខែមករាឆ្នាំ២០១៤ ជាមួយចលនាគៀងគរបាតុកម្ម និងផែនការហែរក្បួនដែលដឹកនាំដោយគណបក្សសង្គ្រោះជាតិ បានទាក់ទាញប្រជាពលរដ្ឋជាច្រើនរយពាន់នាក់ចូលរួម ធ្វើឲ្យអាជ្ញាធរនិងកម្លាំងសន្តិសុខ បានប្រើប្រាស់កម្លាំងមិនចាំបាច់និងជ្រុលហួសហេតុ ដើម្បីបញ្ចប់បាតុកម្មទាំងនោះ។

នៅថ្ងៃទី២ខែមករា ២០១៤ ទាហានបានប៉ះទង្គិចដ៏ហិង្សាជាមួយកម្មករកូដកម្មនៅរោងចក្រយ៉ាកជីន (កម្ពុជា) ដែលស្ថិតនៅជាយ រាជធានីភ្នំពេញ ហើយនៅថ្ងៃទី៣ ខែមករា ប្រជាពលរដ្ឋបួននាក់ត្រូវបានទាហានបាញ់ស្លាប់ ខណៈពេលដែលពួកទាហានសន្តិសុខទាំងនោះ បានចាប់ផ្តើមបាញ់ប្រហារលើបាតុករ នៅលើដងវិថីវេងស្រេងទីកន្លែងដែលការប្រជុំគ្នាបានប្រែក្លាយជាហិង្សា។ អ្នកទីប្រាំ មានអាយុ១៦ឆ្នាំ ឈ្មោះ ខឹមសុផាត ត្រូវបានគេឃើញចុងក្រោយ ដែលដេកនៅលើដងវិថី ជាមួយស្នាមត្រូវគ្រាប់កាំភ្លើងយ៉ាងច្បាស់ នៅលើដើមទ្រូងរបស់គាត់ ដែលនៅបាត់ខ្លួន ដែលគេសន្និដ្ឋានថាបានស្លាប់។ មនុស្សទីប្រាំមួយ ដែលអ្នកឈរមើលហេតុការណ៍នៅលើដងវិថីតែមួយនោះ  បានឃើញពួកកម្លាំងសន្តិសុខវាយប្រហារលើគាត់ ត្រូវបានគេរាយការណ៍មកថា បានទទួលរងការវាយស្រាំខួរក្បាល និងបានស្លាប់នៅក្នុងខែឧសភាឆ្នាំ២០១៤[3]។ យ៉ាងហោចណាស់ប្រជាពលរដ្ឋ២៨នាក់ ត្រូវបានគេវាយដំយ៉ាងធ្ងន់ធ្ងរ និងចាប់ខ្លួនដោយពួកកម្លាំងសន្តិសុខ នៅរោងចក្រយ៉ាកជីន និងតាមដងវិថីវេងស្រេងក្នុងរយៈពេលបាតុកម្មពីរថ្ងៃនោះ។ ការស្លាប់នៅផ្លូវវេងស្រេង បានកើតឡើងបន្ទាប់ពី មនុស្សពីរនាក់បានស្លាប់ដោយសារការប្រើកម្លាំងប្រល័យរបស់កងកម្លាំងសន្តិសុខ នៅទីកន្លែងបាតុកម្មពីរដាច់ពីគ្នាក្នុងឆ្នាំ២០១៣[4]។ ជាក់ស្តែងសមាជិកសន្តិសុខក៏រងរបួសនៅក្នុងឧប្បត្តិហេតុខ្លះផងដែរ[5]។

នៅថ្ងៃទី៤ ខែមករា ២០១៤ ក្រសួងមហាផ្ទៃបានចេញប្រកាសហាមឃាត់មិនកំណត់មួយ

---

[3]មួន សុខមាន អាយុ២៩ឆ្នាំ។ សូមមើលអត្ថបទ៖ មាជ ដារា និងអាលេច កុងសូលីយ៉ូ ស្តីពី "ប្រាំខែមកហើយ សាក្សីរំឭកពីការវាយមួនសុខជា" ចុះផ្សាយក្នុងកាសែតឌឺឃែមបូឌា ដេលី ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៤។
[4] មៅ សុខចាន់ ត្រូវបានបាញ់សម្លាប់នៅថ្ងៃទី១៥ កញ្ញា ២០១៣ និង អេង សុខុម ត្រូវបាន សម្លាប់នៅថ្ងៃទី១២ វិច្ឆិកា ២០១៣

[5] ជួបប្រជុំជាមួយសមាជិកជាន់ខ្ពស់នគរបាលជាតិ, ៥ ឧសភា ២០១៣

មិនឲ្យធ្វើបាតុកម្មជាសាធារណៈ[6]។ ការហាមឃាត់នោះមិនសមស្របទាល់តែសោះ និងផ្ទុយទៅវិញ នៅពេលនោះ ការអនុវត្តដ៏ហិង្សាបានបន្តដល់ពាក់កណ្តាលឆ្នាំ២០១៤។

បន្ទាប់មក ក្នុងឆ្នាំដដែលនោះ គឺថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៤ អាជ្ញាធរបានដាក់របាំងបិទសួនសេរីភាព - ដែលជាផ្នែកមួយក្នុងរាជធានីភ្នំពេញ ដែលគេរៀបចំជាទីកន្លែងស្របច្បាប់មួយ សម្រាប់ការធ្វើបាតុកម្មជាសាធារណៈ - ហើយទីលាននោះបានបន្តបិទរហូតដល់ថ្ងៃទី៦ ខែសីហា។ របាំងទាំងនោះ ត្រូវបានគេយកចេញវិញ បន្ទាប់ពីគណបក្សសង្គ្រោះជាតិ យល់ព្រមបញ្ចប់ពហិការបស់ក្នុងការចូលរួមក្នុងរដ្ឋសភាជាតិ និងក្រោយពីការសម្រេចដល់កិច្ចព្រមព្រៀងនយោបាយ នៅថ្ងៃទី២២ ខែកក្កដា ជាមួយគណបក្សប្រជាជនកម្ពុជាដែលកំពុងតែគ្រប់គ្រងអំណាច។

បន្ទាប់ពីមួយរយៈខ្លី ក្នុងការរឹតបន្តឹងសន្តិសុខលើការជួបប្រជុំត្រូវបានបន្ធូរបន្ថយ ការបង្ក្រាបថ្មីមួយក៏ចាប់ផ្តើមឡើងវិញទៅលើសេរីភាពនៃការជួបប្រជុំដោយសន្តិវិធី នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៤ ក្នុងអំឡុងពេលនោះ មនុស្ស១៧ រូប មានជាអាទ៍អ្នកការពារសិទ្ធិលំនៅដ្ឋាន[7] ព្រះសង្ឃ[8]និងមន្ត្រីនៃគណបក្សសង្គ្រោះជាតិ និងសកម្មជន[9] ត្រូវបានគេចាប់ឃុំខ្លួនអស់រយៈពេលប្រាំបួនថ្ងៃ[10]។ មនុស្សដប់មួយនាក់ក្នុងចំណោម១៧នាក់ ត្រូវបានគេចោទប្រកាន់ នាំទៅតុលាការ និងកាត់ទោសនៅថ្ងៃបន្ទាប់ពីការចាប់ខ្លួនរបស់ពួក

[6]សេចក្តីប្រកាសព័ត៌មានរបស់ក្រសួងមហាផ្ទៃ ថ្ងៃទី៤ ខែមករា ឆ្នាំ២០១៤។ សូមមើលអត្ថបទ កូលីន មីយិន និងភួងបុប្ផា ស្តីពី "រដ្ឋាភិបាលទទួលរងការស្តីបន្ទោសចំពោះការបណ្តេញចេញសួនសេរីភាព" ចុះផ្សាយក្នុងកាសែតឌឹខ្មែរបូខា ដេលី ថ្ងៃទី៦ ខែមករា ឆ្នាំ២០១៤។

[7]អង្គការលើកលែងទោសអន្តរជាតិ,សកម្មភាពជាបន្ទាន់, សកម្មជនការពារសិទ្ធិជាស្ត្រីនិងព្រះសង្ឃត្រូវគេកាត់ទោស (លិបិក្រម ASA 23/007/2014), ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៤ នៅគេហទំព័រ https://www.amnesty.org/en/documents/asa23/007/2014/en/.

[8]អង្គការលើកលែងទោសអន្តរជាតិ, សកម្មភាពបន្ទាន់, សកម្មជនការពារសិទ្ធិជាស្ត្រីនិងព្រះសង្ឃត្រូវគេកាត់ទោស (លិបិក្រម ASA 23/007/2014), ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៤។

[9] អង្គការលើកលែងទោសអន្តរជាតិ,សកម្មភាពបន្ទាន់, សកម្មជនការពារសិទ្ធិជាស្ត្រីនិងព្រះសង្ឃត្រូវគេកាត់ទោស (លិបិក្រម ASA 23/007/2014), ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៤។

[10]អង្គការលីកាដូ "*អង្គការលីកាដូអំពាវនាវឲ្យដោះលែងបុរសនិងស្ត្រីទាំង១៩នាក់ ដែលត្រូវគេដាក់គុកមិនត្រឹមត្រូវ ក្នុងពន្ធនាគារព្រៃស CC1 និង CC2*ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៤ នៅគេហទំព័រhttp://www.licadho-cambodia.org/pressrelease.php?perm=366.

គេ និងទទួលការកាត់ទោសដាក់គុកជាអតិបរមា[11]។ រួមជាមួយមន្ត្រីស្រុក និងសកម្មជនគណបក្សសង្គ្រោះជាតិ ដែលគេចាប់ខ្លួនដាច់ដោយឡែកពីគ្នា ក្នុងខែកញ្ញា និងតុលា ឆ្នាំ២០១៤ បូកនឹងមនុស្ស១៧នាក់ដែលចាប់ខ្លួនក្នុងខែវិច្ឆិកា បានបង្កើនការចាប់ខ្លួនសកម្មជននយោបាយនិងសកម្មជនសិទ្ធិមនុស្សរហូតដល់១៩នាក់ ដាក់គុករហូតទាល់តែក្រោយពេលមានកិច្ចព្រមព្រៀងរវាងគណបក្សសង្គ្រោះជាតិ និងគណបក្សប្រជាជនកម្ពុជា[12]។ កិច្ចព្រមព្រៀងបន្ថែមរវាងគណបក្សសង្គ្រោះជាតិនិងគណបក្សប្រជាជនកម្ពុជាក្នុងឆ្នាំ២០១៥ បាននាំឲ្យមានការដោះលែងមនុស្ស ៨ នាក់ក្នុងចំណោមមនុស្សទាំងដប់ប្រាំបួន ហើយនៅថ្ងៃទី១១ ខែមេសា សកម្មជនដីធ្លីស្ត្រីចំនួនដប់នាក់ត្រូវបានដោះលែងបន្ទាប់ពីមានការលើកលែងទោសដោយព្រះមហាក្សត្រ សីហមុនី[13] និងនៅថ្ងៃទី១៣ ខែមេសា មនុស្សប្រាំបីនាក់ផ្សេងទៀត ក្នុងនោះមានព្រះសង្ឃបីអង្គ និងមន្ត្រីនិងសកម្មជនគណបក្សសង្គ្រោះជាតិចំនួនប្រាំនាក់ ត្រូវបានដោះលែងដោយមានការការធានា[14]។ នៅថ្ងៃទី២៤ មេសា កញ្ញាលី ស៊ាវមិញដែលជាអ្នកទី១៩ ត្រូវបានដោះលែងដោយមានការធា

---

[11]អង្គការលីកាដូ "*អង្គការលីកាដូអំពាវនាវឲ្យដោះលែងបុរសនិងស្ត្រីទាំង១៩នាក់ ដែលត្រូវគេដាក់គុកមិនត្រឹមត្រូវ ក្នុងពន្ធនាគារព្រៃស CC1 និង CC2*ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៤។

[12]មនុស្សទាំង១៩នាក់ តាមលំដាប់នៃការចាប់ខ្លួន មានជាអាទិ៍៖ ស៊ុមពុទ្ធី សមាជិកក្រុមប្រឹក្សាខណ្ឌច្បារអំពៅរបស់គណបក្សសង្គ្រោះជាតិ, អ៊ុកពេចន៍សំណាង សកម្មជនថ្នាក់ក្រោមរបស់គណបក្សសង្គ្រោះជាតិ និងសកម្មជនសហគមន៍បឹងកក់ មានជាអាទិ៍៖ ងែត ឃុន, ទេព វណ្ណី, សុងស្រីលាប, គង់ចន្ថា, ផាន់ឈន់រ៉េត, ប៉ូឆវី, និងនងស្រេង ហើយលោក មាជសុវណ្ណារ៉ា ប្រធាននាយកដ្ឋានព័ត៌មានរបស់គណបក្សសង្គ្រោះជាតិ និងហេងពេជន៍, អ៊ឹមស្រីទូច, និងភួងសុភាព ជាសកម្មជនសិទ្ធិខាងលំនៅដ្ឋានពីសហគមន៍បឹងកក់និងថ្មគោល និងព្រះភិក្ខុ សេងហៃ ជាព្រះសង្ឃ និងកែឃីម ជាអ្នករត់ម៉ូតូកង់បី និងជាអ្នកគាំទ្រគណបក្សសង្គ្រោះជាតិ និងព្រះភិក្ខុ ឃិតវណ្ណៈ និងព្រះភិក្ខុ សាងកុសល ជាព្រះសង្ឃ និងទេពណារិន ជាសមាជិកយុវជនគណបក្សសង្គ្រោះជាតិ និងលីសៀវមិញ អ្នកភូមិនៅខណ្ឌទួលគោក ដែលគ្រួសាររបស់គាត់ ត្រូវបានគេចាក់សោរបិទ ក្នុងទំនាស់ដីធ្លីជាមួយក្រុមហ៊ុនឯកជនពាក់ព័ន្ធដ៏ល្បីល្បាញមួយ។ សូមមើលអង្គការលីកាដូ "*អង្គការលីកាដូអំពាវនាវឲ្យដោះលែងបុរសនិងស្ត្រីទាំង១៩នាក់ ដែលត្រូវគេដាក់គុកមិនត្រឹមត្រូវ ក្នុងពន្ធនាគារព្រៃស CC1 និង CC2*ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៤។

[13]អង្គការលីកាដូ  ព័ត៌មានទាន់ហេតុការណ៍*សកម្មជនបឹងកក់១០នាក់ ត្រូវបានគេដោះលែងបន្ទាប់ពីមានព្រះរាជលើកលែងទោស ការដោះលែងបន្ថែមទៀតអាចនឹងកើតមាន*  ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៥ នៅគេហទំព័រhttp://www.licadho-cambodia.org/flashnews.php?perm=122.

[14]ព័ត៌មានសំខាន់ទាន់ហេតុការណ៍របស់អង្គការលីកាដូ *សមាជិកប្រាំរូបរបស់គណបក្សសង្គ្រោះជាតិ និងព្រះសង្ឃដែលគេផ្សឹកបីអង្គ ត្រូវបានដោះលែងបន្ទាប់ពីមានការចរចារនយោបាយ* ចុះថ្ងៃទី១៣ ខែមេសា ឆ្នាំ២០១៥ នៅគេហទំព័រhttp://www.licadho-cambodia.org/flashnews.php?perm=123.

នា។ គាត់ជាពលរដ្ឋនៅខណ្ឌទួលគោក នៅរាជធានីភ្នំពេញដែលក្រុមគ្រួសាររបស់គាត់មានជម្លោះដីធ្លីជាមួយក្រុមហ៊ុនឯកជនមួយដែលមានឥទ្ធិពល។[15]

ប៉ុន្តែ ទោះបីជាការខិតខំប្រឹងប្រែងជាញឹកញាប់របស់អាជ្ញាធរក្នុងការរឹតបន្តឹង ហើយពេលខ្លះ មានអំពើហិង្សាបង្ក្រាបការប្រជុំក៏ដោយ ក៏ប្រជាពលរដ្ឋក្នុងប្រទេសកម្ពុជា បន្តធ្វើដំណើរទៅកាន់ដងវិថី ដើម្បីបញ្ជាក់ពីការរួបរួមរបស់ពួកគេ។ ពួកគេហាក់ដូចជាបង្ហាញពីឆន្ទៈរបស់ខ្លួនកាន់តែច្រើន ក្នុងការនិយាយប្រឆាំងនឹងភាពអយុត្តិធម៌ដែលគេបានឃើញ។ ក្នុងរាជធានីភ្នំពេញ បាតុកម្មទាក់ទងនឹងដីធ្លី ការងារ បរិស្ថាន និងបញ្ហាផ្សេងៗទៀតបានក្លាយជា  បាតុភូតប្រចាំសប្តាហ៍ ហើយពេលខ្លះស្ទើរតែប្រចាំថ្ងៃទៅហើយ។ អ្នកដែលរស់នៅក្នុងភូមិ និងទីប្រជុំជនដាច់ស្រយាលតាមបណ្តាខេត្តនានា កំពុងតែចែករំលែកព័ត៌មានគ្នា តាមរយៈបណ្តាញសហគមន៍ថ្មី និងបណ្តាញដែលកំពុងបង្កើតឡើងដោយប្រើប្រាស់    បច្ចេកវិទ្យាទំនាក់ទំនងថ្មី - និងកំពុងធ្វើការតវ៉ារួមគ្នា ដើម្បីការពារដីធ្លី និងធនធាន ដែលពួកគេពឹងអាស្រ័យ ដើម្បីជីវភាពរស់នៅជាប្រពៃណីរបស់ពួកគេ។ តាមរយៈការធ្វើកូដកម្មជាបន្តបន្ទាប់  កម្មករនិងសហជីពនានា បានបន្តបង្ហាញពីឥទ្ធិពលរបស់ពួកគេ។ ចំណែកឯយុវជនកម្ពុជា - ដែលជាក្មេងកើតក្រោយរបបខ្មែរក្រហម[16]" - បានបង្កើតវេទិការថ្មីៗ រួមគ្នាដេញដោលពីអនាគតរបស់ប្រទេសដែលត្រូវតែមានការផ្លាស់ប្តូរដ៏ឆាប់រហ័សក្នុងពេលអនាគត។

* * *

របាយការណ៍នេះ បង្ហាញពីលទ្ធផលស្រាវជ្រាវរបស់អង្គការលើលលែងទោសអន្តជាតិទាក់ទងទៅនឹងភាពច្របូកច្របល់នៅប្រទេសកម្ពុជា ជាងពីរឆ្នាំកន្លងមកនេះ ដែលអាជ្ញា

[15] របាយការណ៍ទាន់ហេតុការរបស់អង្គការលីកាដូ *ការដោះលែងចុងក្រោយ "អ្នកទី១៩" លី ស៊ាវមិញ ត្រូវបានដោះលែងដោយមានការធានាដោយតុលាការកំពូល* ថ្ងៃទី២៩ មេសា២០១៥។ មាននៅគេហទំព័រ http://www.licadho-cambodia.org/flashnews.php?perm=124.

[16]សុផាត សឿង "កំណើនឥទ្ធិពលនៃព័ត៌មានបណ្តាញសង្គមលើនយោបាយកម្ពុជា" ព្រឹត្តបត្រអាស៊ីប៉ាស៊ីហ្វិចមណ្ឌលកើតលិច លេខ២២២ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៣។

ធរ រួមទាំងរាជរដ្ឋាភិបាល រដ្ឋអំណាចមូលដ្ឋាន និងកងកម្លាំងសន្តិសុខ បានដាក់ការរឹតត្បិតយ៉ាងធ្ងន់ធ្ងរ និងការរំលោភបំពានសិទ្ធិសេរីភាពក្នុងការជួបប្រជុំគ្នាដោយសន្តិវិធី - ពោលគឺសិទ្ធិបានចែងនៅក្នុងសន្ធិសញ្ញាសិទ្ធិមនុស្សសំខាន់ៗដែលកម្ពុជាជាភាគី និងសិទ្ធិដែលបានចែងនៅក្នុងរដ្ឋធម្មនុញ្ញរបស់ប្រទេស។

លទ្ធផលរកឃើញ គឺផ្អែកលើបទសម្ភាសន៍ជាមួយអ្នករងរបួសក្នុងអំឡុងពេលប្រជុំគ្នា ហើយក្រុមគ្រួសាររបស់ពួកគេ សមាជិកគ្រួសារខ្លះត្រូវបានសម្លាប់អំឡុងពេលបាតុកម្ម សកម្មជននយោបាយ អតីតអ្នកជាប់ឃុំឃាំង តំណាងក្រុមចំណាប់អារម្មណ៍នៃសហគមន៍ សមាជិកប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន តំណាងអង្គការក្រៅរដ្ឋាភិបាល មេដឹកនាំសហជីព អ្នកច្បាប់ មន្ត្រីអង្គការសហប្រជាជាតិ និងព្រះសង្ឃ និងការស្រាវជ្រាវនៅការិយាល័យ ការតាមដានប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ដែលបានធ្វើឡើងចន្លោះខែវិច្ឆិកា ២០១៣ និងឧសភា ២០១៥។ ក្រៅពីនេះ គឺមានការជួបប្រជុំនៅក្នុងខែឧសភា ២០១៥ ជាមួយមន្ត្រីជាន់ខ្ពស់នគរបាលជាតិនៃក្រសួងមហាផ្ទៃ និងជាមួយមន្ត្រីជាន់ខ្ពស់ម្នាក់នៃក្រសួងយុត្តិធម៌។ ការខិតខំប្រឹងប្រែងក្នុងការរៀបចំការប្រជុំជាមួយមន្ត្រីរដ្ឋាភិបាលដទៃទៀតដើម្បីពិភាក្សាគ្នា គឺមិនបានសម្រេចទេ។ អង្គការលើកលែងទោសអន្តរជាតិបានផ្តល់របាយការណ៍ព្រាងដល់រាជរដ្ឋាភិបាលកម្ពុជា ក៏ប៉ុន្តែរដ្ឋាភិបាលពុំបានផ្តល់សេចក្តីអត្ថាធិប្បាយលម្អិតណាមួយទេ។

របាយការណ៍នេះ លាតត្រដាងឲ្យឃើញពីគំរូនៃការរំលោភបំពាន មានជាអាទិ៍ ការដាក់កំហិតបំពានតាមអំពើចិត្តលើសេរីភាពជួបប្រជុំគ្នាដោយសន្តិភាព ការប្រើប្រាស់កម្លាំងមិនចាំបាច់និងហួសហេតុដោយកងកម្លាំងសន្តិសុខលើការជួបប្រជុំ វប្បធម៌និទណ្ឌភាពជុំវិញការរំលោភសិទ្ធិមនុស្ស ដែលប្រព្រឹត្តនៅក្នុងបរិបទនៃជួបប្រជុំ និងការប្រើប្រាស់ប្រព័ន្ធតុលាការ ដើម្បីយាយីរំខានមនុស្សទាំងឡាយណាដែលបានរៀបចំ និងចូលរួមនៅក្នុងការប្រជុំទាំងនោះ។

# ការដាក់កំហិតតាមអំពើចិត្តលើ សេរីភាពជួបប្រជុំដោយសន្តិវិធី

ច្បាប់សិទ្ធិមនុស្សអន្តរជាតិតម្រូវថា ការដាក់កំហិតលើសិទ្ធិសេរីភាពជួបប្រជុំដោយសន្តិវិធី ត្រូវតែបំពេញតាមធាតុបី គឺនីត្យានុកូលភាព គោលបំណងស្របច្បាប់ និងភាពចាំបាច់។ ប៉ុន្តែ ទោះបីជាសេចក្តីសន្មត់ក្នុងច្បាប់កម្ពុជាឆ្នាំ២០០៩ ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី ដែលតម្រូវឲ្យប្រជុំមានការអនុញ្ញាតក៏ដោយ ក៏អាជ្ញាធរបានដាក់កំហិតបំពានតាមអំពើចិត្ត និងពេលខ្លះ បានហាមឃាត់ទាំងស្រុងតែម្តង។ របាយការណ៍នេះ ផ្តល់នូវឧទាហរណ៍នៃការជ្រៀតជ្រែក បូករួមទាំងបំណងបង្ករឧបសគ្គ និងការបំបែកការប្រជុំ។ របាយការណ៍នេះ ក៏ផ្តល់នូវឧទាហរណ៍នៃការដាក់កំហិតលើការបណ្តុះបណ្តាល ការប្រជុំ និងវេទិកាសាធារណៈ ដែលអត់មានតម្រូវឲ្យជូនដំណឹង តាមច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធីទាល់តែសោះ។

# ការប្រើប្រាស់កម្លាំងមិនចាំបាច់ និងជ្រុលហួសហេតុ

អ្នករៀបចំ និងអ្នកចូលរួម ដែលមិនអើពើនឹងការប៉ុនប៉ងដាក់កំហិត ឬហាមឃាត់ការជួបជុំដោយសន្តិវិធី បានដឹងខ្លួនឯងក្នុងការប្រឈមមុខដោយត្រង់ជាមួយកងកម្លាំងសន្តិសុខដែលបានត្រៀមស្រេចទៅហើយក្នុងការប្រើប្រាស់កងកម្លាំងមិនចាំបាច់និងហួសហេតុប្រឆាំងអ្នកចូលរួមប្រជុំ ដែលជាញឹកញាប់ បានបង្ករឱ្យមានការរងរបួស ហើយពេលខ្លះរហូតដល់ស្លាប់។ការប្រជុំភាគច្រើន ដែលដាក់ក្រោមការត្រួតពិនិត្យក្នុងរបាយការណ៍នេះ គឺជាការប្រជុំដោយសន្តិវិធី និងគ្មានយុត្តិកម្មណាមួយសម្រាប់អាជ្ញាធរក្នុងការប្រើកម្លាំងនោះឡើយ។ មានបទដ្ឋានអន្តរជាតិច្បាស់លាស់ អំពីពេលនិងទំហំដែលត្រូវប្រើកងកម្លាំងនិងអាវុធ។ បទដ្ឋានទាំងនេះ មិនត្រូវបានដាក់បញ្ចូលពេញលេញទៅក្នុងច្បាប់ជាតិរបស់កម្ពុជាទេ ហើយគោលការណ៍ស្នូលស្តីពីនីត្យានុកូលភាព ភាពចាំបាច់ និងសមាមាត្រនៃការប្រើកម្លាំងនិងអាវុធ មិនត្រូវបានអើពើដោយកម្លាំងសន្តិសុខជាញឹកញាប់។ ចាប់តាំងពីការបោះឆ្នោតសភាជាតិខែកក្កដាឆ្នាំ២០១៣ កងកម្លាំងសន្តិសុខបានបាញ់

សម្លាប់យ៉ាងហោចណាស់មនុស្សប្រាំមួយនាក់[17]អំឡុងពេលធ្វើបាតុកម្ម និងបានធ្វើរងរបួសយ៉ាងធ្ងន់ធ្ងរជាច្រើននាក់ទៀត។ របាយការណ៍នេះ បានកំណត់ និងវិភាគលើផ្នែកនៃការព្រួយបារម្ភចំនួនប្រាំជាពិសេសទាក់ទងទៅនឹងការប្រើប្រាស់កម្លាំងមិនចាំបាច់ និងហួសហេតុ មានជាអាទ៍អំពើហិង្សាបង្ករដោយក្រុមជំនួយរបស់រដ្ឋ - គឺ "កងកម្លាំងប្រជាការពារខណ្ឌ" ដែលល្បីប្រព្រឹត្តរឿងអាសោច ការកំណត់គោលដៅហិង្សាលើអ្នកកាសែត និងអ្នកឃ្លាំមើលសិទ្ធិមនុស្ស អំពើហិង្សាក្នុងការចាប់ខ្លួន ការប្រើប្រាស់ឧបករណ៍និងអាវុធខុសច្បាប់ និងការប្រើប្រាស់មិនសមហេតុផលនៃកងកម្លាំងពិឃាត។

# និទណ្ឌភាព

នៅក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិ ប្រទេសកម្ពុជាត្រូវផ្តល់សំណងដល់ជនរងគ្រោះនៃការរំលោភសិទ្ធិមនុស្ស និងដាក់ជនដែលទទួលខុសត្រូវចំពោះអំពើរំលោភ ឲ្យទទួលខុសត្រូវចំពោះមុខច្បាប់។ ប៉ុន្តែ ខណៈពេលដែលពាក្យបណ្តឹងជាច្រើនត្រូវបានដាក់ជូនទៅតុលាការ ដោយជនរងគ្រោះនៃការប្រើប្រាស់កម្លាំងមិនចាំបាច់និងហួសកម្រិតរបស់កងសន្តិសុខក្នុងអំឡុងពេលប្រជុំ ពាក្យបណ្តឹងទាំងនេះជាទូទៅ មិនបាននាំឲ្យមានការកាត់ទោសព្រហ្មទណ្ឌលើជនដែលទទួលខុសត្រូវនោះឡើយ។ របាយការណ៍នេះ ពិនិត្យមើលពីរបៀបដែលការស៊ើបអង្កេតអត់តម្លាភាពនិងមិនច្បាស់លាស់របស់មន្ត្រី លើការបាញ់សម្លាប់យ៉ាងហោចណាស់មនុស្ស៦នាក់នៅក្នុងឆ្នាំ២០១៣ និងឆ្នាំ២០១៤។ គ្មានលទ្ធផល គ្មានការរកឃើញ គ្មានវិធានការព្រហ្មទណ្ឌ ឬគ្មានការដាក់វិន័យណាមួយ កើតចេញពីការស៊ើបអង្កេតទាំងនោះ ត្រូវបានគេប្រកាសជាសាធារណៈទេ។ ស្រដៀងគ្នានេះដែរ គ្មានព័ត៌មានណាមួយ ត្រូវបានចែករំលែកប្រាប់ពីចំណាត់ការបន្តស៊ើបអង្កេតករណីបាត់

[17]មនុស្សប្រាំមួយនាក់ត្រូវបានគេសម្លាប់ រួមទាំងម៉ៅសុខចាន់ (អាយុ២៩) សម្លាប់នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៣។ អេងសុខុម (អាយុ៤៩) សម្លាប់នៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៣ និងយឹមផលលាប (អាយុ២៥) សំភ័រី (អាយុ២៥) យានរិទ្ធី (អាយុ២៥) និងផេងកុសល (អាយុ២២) ទាំងអស់ត្រូវបានសម្លាប់នៅថ្ងៃទី៣ ខែមករា ឆ្នាំ២០១៤។ បន្ថែមលើសនេះទៀត អង្គការលើកលែងទោសអន្តរជាតិ នៅតែមានកង្វល់ពីការបាត់ខ្លួនក្មេងប្រុសខែមសុផាត អាយុ១៦ឆ្នាំ។ ពេលចុងក្រោយដែលគេបានឃើញគាត់គឺនៅថ្ងៃទី៣ ខែមករា ឆ្នាំ២០១៤ ដេកស្តូកនៅលើដងផ្លូវវែងស្រេង ជាមួយស្នាមត្រូវគ្រាប់កាំភ្លើងលើដើមទ្រូង។ គាត់កំពុងតែបាត់ខ្លួន និងត្រូវសន្មត់ថាបានស្លាប់ហើយ (សូមមើលជំពូក៦ សម្រាប់ព័ត៌មានបន្ថែម)។

ខ្លួនរបស់ក្មេងប្រុស ខឹម សុផាត អាយុ១៦ឆ្នាំ ដែលបានបាត់ខ្លួន និងដែលសន្មត់ថាបានស្លាប់ បន្ទាប់ពីពួកកម្លាំងសន្តិសុខបានបើកការបាញ់រះលើក្រុមបាតុករនៅរាជធានីភ្នំពេញ នៅថ្ងៃទី៣ ខែមករា ឆ្នាំ២០១៤។ ជាលទ្ធផលនៃកង្វះការទទួលខុសត្រូវនេះ ជនរងគ្រោះ និងក្រុមគ្រួសាររបស់ពួកគេភាគច្រើន មិនត្រូវបានផ្តល់ឱ្យនូវសំណង ដោយរដ្ឋាភិបាល ឬជនល្មើសនៃអំពើហិង្សានោះទេ។

# ការយាយីតាមផ្លូវតុលាការ

អ្នកទាំងឡាយណាដែលបានរៀបចំ និងចូលរួមក្នុងការប្រជុំ ទទួលរងនូវការចាប់នាំខ្លួនទៅកាត់ទោសព្រហ្មទណ្ឌជាញឹកញាប់ និងការយាយីបំពានផ្សេងទៀត។ ទាំងច្បាប់សិទ្ធិមនុស្សអន្តរជាតិនិងច្បាប់កម្ពុជា ត្រូវការពារសិទ្ធិរួចផុតពីការចាប់ខ្លួនតាមអំពើចិត្ត និងការផ្តល់សិទ្ធិទទួលបានការកាត់ក្តីដោយយុត្តិធម៌នៅចំពោះមុខតុលាការឯករាជ្យ។ មានភាពខុសគ្នាយ៉ាងច្បាស់ អំពីអំពើលំអៀងយ៉ាងជាក់ស្តែង ដែលព្រះអាជ្ញាកម្ពុជា តាមចោទប្រកាន់ឲ្យខានតែបានប្រឆាំងនឹងអ្នកចូលរួមនិងរៀបចំការប្រជុំ និងកង្វះមនសិការស៊ើបអង្កេត និងកាត់ទោសជនល្មើសដែលប្រើប្រាស់កម្លាំងមិនចាំបាច់ និងហួសហេតុក្នុងពេលល្បាតការប្រជុំ។ របាយការណ៍នេះបង្ហាញពីការប្រើប្រាស់ខុសនីតិវិធីច្បាប់ រួមទាំងការឃុំខ្លួនមុនការកាត់ក្តី និងការកាត់ទោសព្រហ្មទណ្ឌ បំណងយាយី និងដាក់ទោសអ្នកទាំងឡាយណាដែលដឹកនាំ និងចូលរួមក្នុងការប្រជុំរិះគន់រដ្ឋាភិបាល ទោះជាដោយសន្តិវិធីក៏ដោយ ហើយរបាយការណ៍នេះបង្ហាញថាតុលាការកំពុងតែបរាជ័យក្នុងការប្រកាន់ខ្ជាប់ទៅនឹងបទដ្ឋានអន្តរជាតិស្តីពី សវនាការត្រឹមត្រូវ នៅក្នុងករណីបែបនេះ។

# អនុសាសន៍សំខាន់

របាយការណ៍នេះ បានបញ្ចប់ជាមួយនឹងការអំពាវនាវមួយដល់អាជ្ញាធរកម្ពុជា ឲ្យគោរព ការពារ និងលើកស្ទួយសិទ្ធិសេរីភាពជួបប្រជុំដោយសន្តិវិធី និងផ្តល់អនុសាសន៍ពិស្តារជាបន្តបន្ទាប់សម្រាប់ការផ្លាស់ប្តូរនៅក្នុងច្បាប់ គោលនយោបាយ និងការអនុវត្ត ដើម្បីជួយពួកគេក្នុងការធ្វើដូច្នេះ រួមទាំងអនុសាសន៍សំខាន់ចំនួនដប់ដូចខាងក្រោម ៖

- ធ្វើវិសោធនកម្មលើច្បាប់ស្តីពីការធ្វើបាតុកម្មសន្តិវិធី ដើម្បីឲ្យច្បាប់នេះអនុលោមទៅតាមច្បាប់ និងបទដ្ឋានអន្តរជាតិស្តីពីសិទ្ធិមានសេរីភាពប្រជុំដោយសន្តិវិធី។

- ផ្ទេរការទទួលខុសត្រូវទាំងអស់ពីការល្បាតការប្រជុំគ្នាពីកម្លាំងប្រជាការពារខណ្ឌទៅឲ្យនគរបាល ឬបុគ្គលិកអនុវត្តច្បាប់ផ្សេងទៀត ដែលអំណាចរបស់ពួកគេមានមូលដ្ឋានយ៉ាងច្បាស់នៅក្នុងច្បាប់ និងទៅអ្នកដែលមានការបណ្តុះ បណ្តាលនិងបំពាក់បរិក្ខារសម្រាប់អនុវត្តភារកិច្ចរបស់ខ្លួនស្របតាមច្បាប់និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ជាពិសេសទាក់ទងនឹងការប្រើប្រាស់កម្លាំងនិងអាវុធ។

- អនុម័តច្បាប់ និងចេញបទបញ្ញត្តិអនុវត្តពិស្តារ ដែលកំណត់ក្រមវិន័យគ្រប់ជ្រុងជ្រោយស្តីពីការប្រើប្រាស់កម្លាំងដល់គ្រប់បុគ្គលិកអនុវត្តច្បាប់។ ក្រមវិន័យត្រូវតែអនុលោមនិងឆ្លុះបញ្ចាំងយ៉ាងពេញលេញទៅតាមបទដ្ឋានអន្តរជាតិ រួមទាំងបទវិន័យរបស់អង្គការសហប្រជាជាតិសម្រាប់មន្ត្រីប្រតិបត្តិច្បាប់ និងគោលការណ៍ជាមូលដ្ឋានរបស់អង្គការសហប្រជាជាតិស្តីពីការប្រើប្រាស់កម្លាំងនិងអាវុធដោយមន្ត្រីប្រតិបត្តិច្បាប់នេះ។

- ផ្តល់ការបណ្តុះបណ្តាលដល់បុគ្គលិកអនុវត្តច្បាប់ ក្នុងការគ្រប់គ្រងហ្វូងមនុស្ស អហិង្សា ការវាយតម្លៃពីការគំរាម និងការបន្ធូរបន្ថយភាពតានតឹងនៅក្នុងបរិបទនៃការប្រជុំ។ ការបណ្តុះបណ្តាលក៏ត្រូវតែមានបង្រៀនពីបទវិន័យគ្រប់ជ្រុងជ្រោយស្តីពីការប្រើប្រាស់កម្លាំងនិងអាវុធ សម្រាប់បុគ្គលិកប្រតិបត្តិច្បាប់ទាំងអស់ ដូចដែលបានរៀបរាប់ខាងលើ។

- ធានាថា រាល់ករណីដែលសង្ស័យទាក់ទងនឹងការរំលោភសិទ្ធិមនុស្សនៅក្នុងបរិបទនៃការជួបប្រជុំ ជាពិសេសករណីពាក់ព័ន្ធនឹងការស្លាប់ របួស ឬការរងគ្រោះធ្ងន់ធ្ងរដទៃទៀត ត្រូវបានគេស៊ើបអង្កេតភ្លាម ដោយឯករាជ្យ មិនលម្អៀង និងដោយហ្មត់ចត់។

- ផ្តល់ព័ត៌មានដល់សាធារណៈជន អំពីការស៊ើបអង្កេត រួមទាំងលក្ខខណ្ឌនៃសេចក្តីយោងនាំឲ្យមានការស្លាប់របស់បុគ្គល ដែលគេបានបាញ់សម្លាប់នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៣ ថ្ងៃ១២ ខែវិច្ឆិកា ឆ្នាំ២០១៣, និងថ្ងៃទី៣ ខែមករា ឆ្នាំ២០១៤។

- ចាប់ផ្តើមការស៊ើបអង្កេតពេញលេញមួយ ក្នុងការបាត់ខ្លួនដោយបង្ខំរបស់ក្មេងប្រុស ខឹមសុផាត និងផ្តល់ព័ត៌មានដល់ក្រុមគ្រួសាររបស់គាត់ ដែលតម្រូវឲ្យធ្វើដូច្នេះតាមអនុសញ្ញាអន្តរជាតិសម្រាប់ការការពារមនុស្សទាំងអស់ពីការបាត់ខ្លួនដោយបង្ខំ។

- ធានាថា ជនទាំងឡាយដែលសង្ស័យថាបានទទួលខុសត្រូវប្រព្រឹត្តបទល្មើស ពាក់ព័ន្ធនឹងការរំលោភសិទ្ធិមនុស្សនៅក្នុងបរិបទនៃការជួបប្រជុំ ត្រូវបាននាំខ្លួនកាត់ទោសស្របតាមនីតិវិធីកំណត់តាមបទដ្ឋានអន្តរជាតិស្តីពីភាពយុត្តិធម៌។ ការធានានេះ ត្រូវរួមបញ្ចូលទាំងការនាំខ្លួនមកកាត់ទោសចំពោះជនទាំងឡាយណាដែលបានបញ្ជាឱ្យប្រើអំពើហិង្សា និងជនទាំងឡាយណាដែលបានអនុវត្តបទបញ្ជាទាំងនោះ។

- ធានាថា គ្មានបុគ្គលណាម្នាក់ ត្រូវបានគេចាប់ខ្លួន ចោទប្រកាន់ កាត់ទោស ឬដាក់ពន្ធនាគារ ចំពោះការប្រើប្រាស់សិទ្ធិមនុស្សរបស់ពួកគេ ក្នុងសេរីភាពជួបប្រជុំដោយសន្តិវិធី ការចូលរួមសមាគម និងការបញ្ចេញមតិ។

- ពិនិត្យឡើងវិញនូវនាំខ្លួនមកវិនិច្ឆ័យទោស និងការផ្តន្ទាទោសនៅគ្រប់ករណីពាក់ព័ន្ធទាំងអស់ដែលកំពុងមាន ចាត់ជាមោឃៈចំពោះការកាត់ទោសដែលគ្មានការគាំទ្រតាមផ្លូវច្បាប់ ឬដោយគ្មានភស្តុតាង និងត្រូវដោះលែងជាបន្ទាន់ និងដោយគ្មានលក្ខខណ្ឌនូវអ្នកទាំងឡាយ ដែលត្រូវបានគេដាក់គុកដោយហេតុផលប្រើប្រាស់ដោយសន្តិវិធីនៃសិទ្ធិមនុស្សរបស់ពួកគេ។

# អនុសាសន៍

ជាបន្តទៅនេះគឺជាអនុសាសន៍ពិស្តាររបស់អង្គការលើកលែងទោសអន្តរជាតិ ជូនចំពោះអាជ្ញាធរកម្ពុជា។ អនុសាសន៍ទាំងនេះ មានជាអាទ៍ការផ្លាស់ប្តូរក្នុងច្បាប់ គោលនយោបាយ និងការអនុវត្តន៍ ដើម្បីធានាយុត្តិធម៌សម្រាប់ជនរងគ្រោះនៃការរំលោភសិទ្ធិមនុស្សក្នុងបរិបទនៃការជួបប្រជុំ និងការអនុវត្តន៍នៅពេលអនាគត ស្របទៅតាមច្បាប់និងបទដ្ឋានអន្តរជាតិស្តីពី សិទ្ធិសេរីភាពខាងការប្រជុំ និងសិទ្ធិពាក់ព័ន្ធដទៃទៀត ដែលធានាដោយលិខិតុបករណ៍អន្តរជាតិ ដែលកម្ពុជាជារដ្ឋភាគី រួមទាំងសិទ្ធិមានសវនាការយុត្តិធម៌ សិទ្ធិទទួលដំណោះស្រាយ សិទ្ធិរស់រានមានជីវិត និងសិទ្ធិរួចផុតពីការធ្វើទារុណកម្ម និងការប្រព្រឹត្តឃោរឃៅដទៃទៀត។

## ត្រូវបញ្ចប់ការដាក់កំហិតតាមអំពើចិត្ត នៅលើសិទ្ធិសេរីភាពខាងការប្រជុំដោយសន្តិវិធី

១. ត្រូវអះអាងជាថ្មីនូវការប្តេជ្ញាចិត្តជាសាធារណៈរបស់រដ្ឋាភិបាលក្នុងការគោរព ការពារ និងលើកស្ទួយសិទ្ធិមនុស្ស ក្នុងការមានសេរីភាពជួបប្រជុំដោយសន្តិវិធី ដោយអនុលោមតាមច្បាប់និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ

២. ធ្វើវិសោធនកម្មមាត្រាទី៤១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីឲ្យមូលដ្ឋានសម្រាប់ការដាក់កំហិតលើសិទ្ធិសេរីភាពជួបប្រជុំ ស្របទៅតាមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងនយោបាយ មាត្រាទី ២១។ ជាពិសេស ឃ្លាថា "ដើម្បីរក្សាទំនៀមទំលាប់ល្អរបស់សង្គម" ដែលមិនស្របនឹងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ត្រង់មាត្រាទី២១ គួរតែលុបចេញពីមាត្រាទី៤១។

៣. ធ្វើវិសោធនកម្មច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី ឲ្យស្របតាមច្បាប់អន្តរជាតិ និងបទដ្ឋានស្តីពីសិទ្ធិសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី ដូចខាងក្រោមនេះ ៖

ក. បញ្ចូលការសន្មត់ដែលរហ័សដែលអនុញ្ញាតឲ្យធ្វើបាតុកម្ម និងការជួបប្រជុំដទៃ

ទៀត ដែលស្ថិតក្រោម ច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី ដើម្បីបន្ត ៖

ខ. លុបចោលឃ្លា "ទំនៀមទំលាប់ល្អរបស់សង្គម" ដែលជាមធ្យោបាយមួយ ដើម្បីធ្វើយុត្តិកម្មដល់ការដាក់កំហិតលើសេរីភាពជួបប្រជុំដោយសន្តិវិធី ក្នុងមាត្រាទី២ ។

គ. ធានាថា នីតិវិធីស្តីពីការជូនដំណឹងត្រូវតែអនុវត្តតាមគោលការណ៍ណែនាំដោយអ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិសេរីភាពជួបប្រជុំដោយសន្តិវិធី និងសមាគមនិងមិនត្រូវមានការិយាល័យធិបតេយ្យហួសហេតុពេក ហើយត្រូវចែងពីការជូនដំណឹង ដែលត្រូវធ្វើឡើងនៅក្នុង "វិធីសាមញ្ញនិងលឿនបំផុត" តាមដែលអាចធ្វើបាន មានជាអាទិ៍ ៖

i. កាត់បន្ថយរយៈពេលជូនដំណឹងជាអតិបរមា ឧទាហរណ៍មកត្រឹមចំនួន៤៨ ម៉ោង មុនថ្ងៃជួបប្រជុំដែលគ្រោងនឹងកើតឡើង
ii. កាត់បន្ថយការតម្រូវយកឈ្មោះ ឬអ្នករៀបចំពីបីនាក់មកត្រឹមតែមួយនាក់
iii. លុបចោលតម្រូវការឲ្យផ្តល់អត្តសញ្ញាណផ្លូវការរបស់អ្នករៀបចំ
iv. លុបចោលតម្រូវការឲ្យផ្តល់ព័ត៌មានអំពីចំនួនជាក់លាក់នៃអ្នកចូលរួម ដែលរំពឹងថានឹងចូលរួម
v. សូមចែងពីនីតិវិធីមួយ ដែលឲ្យអ្នករៀបចំបំពេញទម្រង់បែបបទមួយដែលច្បាស់និងសង្ខេបដែលមាននូវព័ត៌មានជាអាទិ៍កាលបរិច្ឆេទពេលវេលា រយៈពេលនិងទីតាំងឬផ្លូវហែរការជួបប្រជុំនិងឈ្មោះអាសយដ្ឋាន និងព័ត៌មានទំនាក់ទំនងពិស្តាររបស់អ្នករៀបចំ។

ឃ. ធានាថា តម្រូវការជូនដំណឹង មិនត្រូវអនុវត្តចំពោះការប្រជុំទាំងឡាយដែលចំនួនអ្នកចូលរួមមិនលើសចំនួនអប្បបរមា ដែលបានបញ្ជាក់នោះទេ ឬចំពោះការប្រជុំទាំងឡាយ ដែលបានកើតឡើងនៅសួនសេរីភាពឬកន្លែងឯកជនឬកន្លែងសម្ភហាភាពនោះទេ។

ង. ទទួលស្គាល់ជាក់ស្តែងចំពោះការប្រជុំដែលកើតឡើងដោយឥតការគ្រោងទុកនិង

លើកលែងពួកគេពីនីតិវិធីជូនដំណឹងនេះ។

ច. ចែងឲ្យបានច្បាស់ថាការប្រជុំនានា នឹងមិនត្រូវបំបែកឡើយ ដោយមិនគិតពីការជូនដំណឹងអ្វីទាំងអស់ ប្រសិនបើការប្រជុំធ្វើដោយសន្តិវិធី និងមិនចោទជាការគំរាមកំហែងដល់សុវត្ថិភាពសាធារណៈសន្តិសុខជាតិសណ្តាប់ធ្នាប់សាធារណៈឬសិទ្ធិនិងសេរីភាពរបស់អ្នកដទៃទេនោះ។

ឆ. លុបចោលរាល់ភាសា ដែលបង្ហាញពីការតម្រូវឲ្យមានការយល់ព្រមពីអាជ្ញាធរសម្រាប់ការជួបប្រជុំនានា រួមទាំងសេចក្តីយោងឲ្យមានការយល់ព្រមក្នុងមាត្រា១០ និងមាត្រា២០ ហើយការប្រើពាក្យ "ត្រូវឆ្លើយតបជាវិជ្ជមាន" នៅក្នុងមាត្រាទី៩ ដែលបង្កប់ន័យឲ្យមានតម្រូវការយល់ព្រម។

ជ. ត្រូវចែងពីនីតិវិធីដោះស្រាយជម្លោះមួយដែលពាក់ព័ន្ធនឹងការសម្រេចចិត្តរបស់អាជ្ញាធរខេត្តឬក្រុងដែលបានដាក់កំហិត ឬដើម្បីបង្ការមិនឲ្យមានការជួបប្រជុំកើតឡើង មានជាអាទ៍ ៖

i. ការតម្រូវឱ្យអាជ្ញាធរផ្តល់ការពន្យល់ជាលាយលក្ខអក្សរយ៉ាងលម្អិតនិងទាន់ពេលវេលា ស្តីពីហេតុផលនៃការដាក់កំហិតលើការជួបប្រជុំ។ ការពន្យល់ត្រូវតែបង្ហាញពីរបៀបនៃការដាក់កំហិតចោទជាបញ្ហា ស្របតាមធាតុទាំងបី មានជាអាទ៍នីត្យានុកូលភាពបំណងតាមផ្លូវច្បាប់និងភាពចាំបាច់។
ii. ការធានាឲ្យអ្នករៀបចំមាននូវសិទ្ធិចូលស្តាប់ដោយផ្ទាល់ខ្លួនឯងឬសិទ្ធិការដាក់ស្នើទៅក្រសួងមហាផ្ទៃប្រឆាំងនឹងសេចក្តីសម្រេចរបស់អាជ្ញាធរខេត្តឬក្រុង។
iii. ការផ្តល់សិទ្ធិប្តឹងឧទ្ធរណ៍ នៅចំពោះមុខស្ថាប័នឯករាជ្យនិងមិនលំអៀង ដូចជាតុលាការប្រឆាំងនឹងសេចក្តីសម្រេចទាំងឡាយរបស់ក្រសួងមហាផ្ទៃក្នុងការប្រកាន់យកការដាក់កំហិត ឬការបង្ការមិនឲ្យការប្រជុំកើតឡើងបាន។

៩. ផ្តល់ការបណ្តុះបណ្តាដល់អាជ្ញាធរក្រុងនិងបណ្តោះអាសន្ន អំពីសិទ្ធិសេរីភាពខាងប្រជុំដោយសន្តិវិធីច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធីនិងការអនុវត្តត្រឹមត្រូវនិងយុត្តិធម៌ជាពិសេសទាក់ទងទៅនឹងការដាក់កំហិតឬការហាមប្រាមលើការប្រជុំ។កម្មវិធីបណ្តុះបណ្តាលនេះគួរតែរួមបញ្ចូលនូវការណែនាំដូចខាងក្រោម ៖

ក. ការដាក់កំហិតលើការប្រជុំផ្សេងៗ ត្រូវតែស្របតាមធាតុទាំងបី ស្តីពីនីត្យានុកូលភាព គោលបំណងស្របច្បាប់និងភាពចាំបាច់។

ខ. ការហាមឃាត់ការជួបប្រជុំ ត្រូវតែជាវិធានការចុងក្រោយបំផុតនិងអាចប្រើបានតែដើម្បីបញ្ចៀសផលវិបាកធ្ងន់ធ្ងរដូចជាអំពើហិង្សាឬការបង្អាក់ដំណើរដ៏រីករាលដាលនៅកន្លែងដែលការឆ្លើយតបតិចតួច លែងសម្រេចដល់គោលដៅស្របតាមច្បាប់ដែលអនុវត្តដោយអាជ្ញាធរ។

គ. អាជ្ញាធរត្រូវតែបញ្ឈប់ការបំបែកការជួបប្រជុំអហិង្សា ដែលគេជូនដំណឹងទៅអាជ្ញាធរហើយនោះ។

ឃ. បទបញ្ញត្តិរបស់ច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី មិនត្រូវយកមកប្រើក្នុងគោលបំណងដើម្បីបង្ហាញពីភាពត្រឹមត្រូវលើការដាក់កំហិតលើរាល់ទម្រង់នៃការប្រមូលផ្តុំដែលមិនស្ថិតក្នុងវិសាលភាពរបស់ច្បាប់ រួមទាំងកូដកម្ម ការជួបជុំសម្រាប់គោលបំណងសាសនាកិច្ចប្រជុំធម្មតា ។ល។

ង. អាជ្ញាធរ ត្រូវតែចាត់វិធានការការពារប្រឆាំងនឹងអំពើបំភិតបំភ័យ និងត្រូវតែបញ្ឈប់អំពើបំភិតបំភ័យប្រឆាំងនឹងម្ចាស់អាជីវកម្មនិងម្ចាស់អចលនទ្រព្យដែលទទួលរៀបចំការជួបប្រជុំនិងការប្រជុំដោយសន្តិវិធីផ្សេងទៀត។

ច. ការចាប់ផ្តើមនៃយុទ្ធនាការបោះឆ្នោតមិនមែនជាហេតុផលត្រឹមត្រូវ ដើម្បីដាក់ការកំហិតលើសេរីភាពជួបប្រជុំដោយសន្តិវិធីនោះឡើយ។

ឆ. អាជ្ញាធរត្រូវតែបញ្ឈប់ពីការឈ្លបយកការណ៍នៅឯកិច្ចប្រជុំដោយសន្តិវិធីនិងវេទិកាសាធារណៈហើយត្រូវបញ្ចប់ការហៅអ្នកចូលរួមមកសួរចម្លើយ បន្ទាប់ពីការចប់ព្រឹត្តការណ៍និងសកម្មភាពទាំងឡាយនេះ។

៥. កែសេចក្តីព្រាងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ មុនពេលដែលសេចក្តីព្រាងនេះ ត្រូវបានឡាយព្រះហត្ថលេខាទៅជាច្បាប់ដោយព្រះមហាក្សត្រក្នុងបំណងឲ្យមាតិកានៃច្បាប់នេះ សមស្របទៅនឹងច្បាប់និងបទដ្ឋានអន្តរជាតិស្តីពីសិទ្ធិសេរីភាពខាងការជួបប្រជុំដោយសន្តិវិធីដូចខាងក្រោម ៖

ក. បញ្ចូលបទបញ្ញត្តិដែលរំឭកឡើងវិញនូវសិទ្ធិសេរីភាពការប្រជុំដោយសន្តិវិធី នៅគ្រប់អំឡុងពេលនៃការធ្វើយុទ្ធនាការបោះឆ្នោតនិងការបោះឆ្នោត

ខ. លុបចោលការដាក់កំហិតជាតួលេខ លើចំនួននៃការហែក្បួននិងការប្រជុំដែលតម្រូវដល់គណបក្សនយោបាយមួយ ត្រូវរៀបចំក្នុងអំឡុងពេលនៃយុទ្ធនាការបោះឆ្នោត

គ. លុបចោលការដាក់កំហិតលើសិទ្ធិសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធីរបស់ក្រុមសង្គមស៊ីវិលរួមទាំងបទបញ្ញត្តិដែលរារាំងពួកគេមិនឲ្យចូលរួមក្នុងការជួបជុំ ឬប្រជុំស្តីពីគណបក្សនយោបាយឬបេក្ខជនណាមួយ។

# ធានាការប្រតិបត្តិច្បាប់ត្រឹមត្រូវ សម្រាប់ការប្រជុំ

៦. រំសាយកងសេនាជនខណ្ឌ និងផ្ទេររាល់ការទទួលខុសត្រូវ ដើម្បីរក្សាសណ្តាប់ធ្នាប់ការប្រជុំផ្សេងៗទៅនគរបាល ឬមន្ត្រីអនុវត្តច្បាប់ផ្សេងទៀត ដែលសិទ្ធិអំណាចរបស់ពួកគេមានចែងក្នុងច្បាប់យ៉ាងច្បាស់លាស់ និងដែលមានការបណ្តុះបណ្តាល និងការបំពាក់គ្រឿងបរិក្ខារ ដើម្បីអនុវត្តភារកិច្ចរបស់ខ្លួនស្របតាមច្បាប់និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ជាពិសេសទាក់ទងទៅនឹងការប្រើប្រាស់កម្លាំងនិងអាវុធ។

៧. បង្កើតគោលនយោបាយជ្រើសរើសនិងបណ្តុះបណ្តាលនិងនិតិវិធីសម្រាប់បុគ្គលិកប្រតិបត្តិច្បាប់ទាំងអស់រួមទាំងនគរបាលជាតិនិងកងរាជអាវុធហត្ថ ដោយអនុលោមតាមបទដ្ឋានអន្តរជាតិ រួមទាំងគោលការណ៍ជាមូលដ្ឋានរបស់អង្គការសហប្រជាជាតិស្តីពីការប្រើប្រាស់កងកម្លាំងនិងអាវុធដោយមន្ត្រីប្រតិបត្តិច្បាប់ (គោលការណ៍ជាមូលដ្ឋានរបស់

អង្គការសហប្រជាជាតិ)រួមទាំងការធានាជាអាទ៍ថា ៖

ក. មន្ត្រីប្រតិបត្តិច្បាប់ត្រូវបាន "ជ្រើសរើសតាមនីតិវិធីត្រួតពិនិត្យត្រឹមត្រូវ" មានកាយ និងសតិសម្បទារសមស្រប" និង "ទទួលបានការបណ្តុះបណ្តាលជាបន្តនិងយ៉ាងហ្មត់ចត់"។

ខ. មន្ត្រីអនុវត្តច្បាប់ត្រូវបានផ្តល់ឱ្យនូវការបណ្តុះបណ្តាលនិងការឆ្លងកាត់ធ្វើតេស្ត ស្របតាមបទដ្ឋានសមត្ថភាពសមស្រប ក្នុងការប្រើប្រាស់កម្លាំង។ក្នុងការផ្តល់វគ្គបណ្តុះបណ្តាលបែបនេះត្រូវតែផ្តល់ការតាំងចិត្តពិសេស លើបញ្ហាក្រមសីលធម៌នគរបាល និងសិទ្ធិមនុស្ស ដើម្បីជាជម្រើសជំនួសឲ្យការប្រើប្រាស់កម្លាំងនិងអាវុធ រួមទាំងការដាក់ឲ្យមានការផ្សះផ្សារជម្លោះដោយសន្តិវិធី ការយល់ពីឥរិយាបថនៃហ្វូងមនុស្សនិងវិធីសាស្ត្របញ្ចុះបញ្ចូល ចរចារនិងការសម្រុះសម្រួល។

គ. សម្បទាររបស់មន្ត្រីប្រតិបត្តិច្បាប់ក្នុងការបំពេញមុខងាររបស់ខ្លួនត្រូវដាក់ក្រោមការត្រួតពិនិត្យឡើងវិញទៅតាមកាលកំណត់។

៨. បោះផ្សាយព័ត៌មានបំភ្លឺអំពីអំណាចបញ្ជារបស់នគរបាលជាតិនិងអន្តរកម្មរវាងអំណាចបញ្ជារបស់នាយករដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ អគ្គស្នងការនគរបាលជាតិនិងអាជ្ញាធរមូលដ្ឋាន។

៩. បញ្ចប់ការប្រើប្រាស់នៃមនុស្សក្នុងសម្លៀកបំពាក់ធម្មតាក្នុងការរក្សាសណ្តាប់ធ្នាប់នៃការប្រជុំ និងធានាអនុវត្តឲ្យបានពេញលេញនូវតម្រូវការដែលមានចែងក្នុងមាត្រា១៩ នៃច្បាប់ស្តីពីការធ្វើបាតុកម្មសន្តិវិធី ដែលថា « អាជ្ញាធរមានសមត្ថកិច្ចដែលដាក់ឲ្យសន្តិសុខសុវត្ថិភាពនិងសណ្តាប់ធ្នាប់សាធារណៈនៅកន្លែងជួបប្រជុំដោយសន្តិវិធីត្រូវស្លៀកពាក់ឯកសណ្ឋានឲ្យបានត្រឹមត្រូវនិងពាក់បង្ហាញផ្លាកឈ្មោះនិងលេខកូដអត្តសញ្ញាណនៅផ្នែកខាងមុខនៃឯកសណ្ឋានរបស់ខ្លួន។

១០. ធានាថា មន្ត្រីប្រតិបត្តិច្បាប់គោរពសិទ្ធិសេរីភាពក្នុងការសម្តែងមតិរបស់អ្នកចូលរួមប្រជុំទាំងអស់និងសិទ្ធិរបស់សាធារណជនក្នុងការទទួលបានព័ត៌មាន ហើយធានាថាអ្នក

សារព័ត៌មាន អាចអនុវត្តការងាររបស់ខ្លួនដោយគ្មានការជ្រៀតជ្រែកមិនសមហេតុផលរួមទាំងការថតសំឡេង និងការផ្សព្វផ្សាយព័ត៌មានស្តីពីព្រឹត្តិការណ៍និងអំពីសកម្មភាពរបស់នគរបាល។

១១. ធានាថាមន្ត្រីប្រតិបត្តិច្បាប់គោរពសិទ្ធិរបស់អ្នកសារព័ត៌មានប្រជាពលរដ្ឋអ្នកឃ្លាំមើលសិទ្ធិមនុស្សនិងសិទ្ធិរបស់ប្រជាពលរដ្ឋសាមញ្ញក្នុងការចងក្រងឯកសារ ការរំលោភសិទ្ធិមនុស្សនៅគ្រប់ពេលនិងគ្រប់ទីកន្លែង ការរំលោភកើតឡើង។

១២. ធានាថាភ្នាក់ងារនិងមន្ត្រីប្រតិបត្តិច្បាប់ទាក់ទងជាមួយអ្នករៀបចំនិងអ្នកចូលរួមប្រជុំនៅមុននិងនៅក្នុងអំឡុងពេលប្រជុំ ដើម្បីបង្កើតការយល់គ្នាទៅវិញទៅមក កាត់បន្ថយភាពតានតឹងនិងជៀសវាងការប្រឈមមុខដាក់គ្នាដែលមិនចាំបាច់និងដើម្បីរកវិធីទប់ស្កាត់អំពើហិង្សា ឬដើម្បីបញ្ឈប់ឧប្បត្តិហេតុបែបណាមួយបានភ្លាមៗមុនពេលផ្ទុះឡើង។

១៣. ធានាថាមន្ត្រីប្រតិបត្តិច្បាប់មិនបានបំបែកការប្រជុំដោយសន្តិវិធី ដោយមានលេសថាពួកគេមិនបានអនុវត្តតាមតម្រូវការជូនដំណឹងជាមុន។

១៤. ធានាថា ការសម្រេចចិត្តណាមួយដើម្បីបំបែកការប្រជុំត្រូវធ្វើស្របនឹងការដាក់កំហិតដែលអនុញ្ញាតដោយច្បាប់សិទ្ធិមនុស្សអន្តរជាតិស្តីពីការប្រជុំនិងធានាថា បទបញ្ជាបំបែកត្រូវបានផ្សាយឲ្យដឹងនិងពន្យល់ច្បាស់លាស់ ដើម្បីទទួលបានឲ្យច្រើនតាមដែលអាចធ្វើទៅបាន នូវការយោគយល់គ្នា និងការយល់ព្រមរបស់បាតុករនិងពេលវេលាគ្រប់គ្រាន់សម្រាប់ពួកគេបំបែកខ្លួន។

១៥. ផ្តល់ការបណ្តុះបណ្តាដល់បុគ្គលិកប្រតិបត្តិច្បាប់ក្នុងការចាប់ខ្លួន ស្របតាមច្បាប់និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ រួមទាំងការរួចផុតពីការចាប់ខ្លួនតាមអំពើចិត្តនិងសិទ្ធិឲ្យគេប្រាប់មកខ្លួនភ្លាមៗនៅពេលមានការចាប់ខ្លួន អំពីហេតុផលនៃការចាប់ខ្លួន ការចោទប្រកាន់ណាមួយប្រឆាំងនឹងខ្លួននិងសិទ្ធិរួចផុតពីការធ្វើទារុណកម្មនិងការប្រព្រឹត្តដ៏ឃោរឃៅផ្សេងទៀត។

# បញ្ចប់ការប្រើប្រាស់កម្លាំងមិនចាំបាច់ និងជ្រុលហួសហេតុ

១៦. អនុម័តច្បាប់និងចេញសេចក្តីណែនាំពិស្តារសម្រាប់ការអនុវត្តដែលមានចែងក្រមសីលធម៌គ្រប់ជ្រុងជ្រោយស្តីពីការប្រើប្រាស់កម្លាំងសម្រាប់គ្រប់បុគ្គលិកប្រតិបត្តិច្បាប់ទាំងអស់។ក្រមសីលធម៌ត្រូវតែអនុលោម និងឆ្លុះបញ្ចាំងបទដ្ឋានអន្តរជាតិដែលពាក់ព័ន្ធ រួមទាំងក្រមសីលធម៌របស់អង្គការសហប្រជាជាតិសម្រាប់មន្ត្រីប្រតិបត្តិច្បាប់ និងគោលការណ៍ជាមូលដ្ឋានរបស់អង្គការសហប្រជាជាតិ។ច្បាប់និងបទបញ្ញត្តិ ត្រូវតែដាក់បញ្ចូលចំណុចដូចខាងក្រោម ៖

ក. បុគ្គលិកប្រតិបត្តិច្បាប់ត្រូវតែអនុវត្តមធ្យោបាយអហិង្សាមុននឹងប្រើប្រាស់កម្លាំង និងអាវុធជាជម្រើសចុងក្រោយ។ពួកគេអាចប្រើកងកម្លាំងនិងអាវុធបាន លុះត្រាតែមធ្យោបាយផ្សេងទៀត លែងមានប្រសិទ្ធភាពឬមិនអាចមានការសន្យាណាមួយ ក្នុងការសម្រេចបានលទ្ធផលគ្រោងទុក។

ខ. ប្រសិនបើការប្រើកងកម្លាំងនិងអាវុធ មិនអាចចៀសផុតទេនោះ បុគ្គលិកប្រតិបត្តិច្បាប់ត្រូវ ៖

i. ប្រើប្រាស់ក្នុងកម្រិតទាបបំផុត និងត្រូវតែសមាមាត្រទៅនឹងភាពធ្ងន់ធ្ងរនៃបទល្មើសនិងស្របតាមកម្មវត្ថុស្របច្បាប់ដែលចង់សម្រេចបាន
ii. កាត់បន្ថយការធ្វើឲ្យរងរបួស និងគោរពនិងការពារជីវិតមនុស្ស
iii. ធានាថាជំនួយរួមទាំងជំនួយវេជ្ជសាស្ត្រត្រូវបានផ្តល់ដល់មនុស្សរងរបួស ឬមនុស្សរងផលប៉ះពាល់ណាមួយនៅពេលដំបូងគេបង្អស់។

គ. បុគ្គលិកប្រតិបត្តិច្បាប់ត្រូវតែប្រើអាវុធ បានត្រឹមតែនៅពេលដែលជនសង្ស័យ ប្រើកាំភ្លើងតបតវិញ ឬម្យ៉ាងទៀតនៅពេលជនសង្ស័យអាចធ្វើឲ្យអ្នកដទៃបាត់បង់ជីវិត និងវិធានការតិចតួចមិនគ្រប់គ្រាន់ដើម្បីទប់ស្កាត់ឬចាប់ជនសង្ស័យប្រព្រឹត្តបទល្មើស។

ឃ.បុគ្គលិកប្រតិបត្តិច្បាប់ មិនត្រូវប្រើអាវុធប្រឆាំងនឹងមនុស្សលើកលែងតែក្នុងការការពារខ្លួនឬការពារអ្នកដទៃ ប្រឆាំងការអាចនឹងស្លាប់ភ្លាមៗ ឬអាចរបួសធ្ងន់ធ្ងរភ្លាមៗ និងនៅពេលដែលវិធានកម្សោយ លែងមានប្រសិទ្ធភាពសម្រេចបាននូវគោលបំណងទាំងនេះ។

ង.ការប្រើប្រាស់អាវុធសម្លាប់ដោយចេតនាអាចធ្វើបានក្នុងកាលៈទេសៈមិនអាចជៀសវាងបានដើម្បីការពារជីវិតមនុស្ស ខណៈដែលមធ្យោបាយផ្សេងទៀត លែងមានប្រសិទ្ធភាពឬលែងបានផលតាមការសន្យាណាមួយ។

ច.ការប្រើប្រាស់កងកម្លាំងនិងអាវុធតាមអំពើចិត្តឬដោយបំពានដោយមន្ត្រីប្រតិបត្តិច្បាប់ ត្រូវតែដាក់ឲ្យទទួលទោសក្រោមក្រមព្រហ្មទណ្ឌ។

ឆ.នៅក្នុងករណីមានការស្លាប់និងរបួសឬផលវិបាកធ្ងន់ធ្ងរដទៃទៀតមានការស៊ើបអង្កេតបន្ទាន់ឯករាជ្យមិនលំអៀងនិងប្រកបដោយប្រសិទ្ធភាពត្រូវតែចាប់ផ្តើមនិងត្រូវមានរបាយការណ៍ពិស្តារមួយផ្ញើទៅកាន់អាជ្ញាធរមានសមត្ថកិច្ច។

ជ.ច្បាប់ឬបទបញ្ញត្តិនានា ត្រូវចែងឲ្យមាននីតិវិធីរាយការណ៍និងត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាព សម្រាប់ឧប្បត្តិហេតុទាំងអស់នៃការប្រើអាវុធដោយមន្ត្រីប្រតិបត្តិច្បាប់ ក្នុងពេលបំពេញភារកិច្ចរបស់ខ្លួន ឬនៅពេលមានការស្លាប់ឬរបួស ដែលបណ្តាលមកពីការប្រើប្រាស់កម្លាំង និងអាវុធដោយមន្ត្រីប្រតិបត្តិច្បាប់។ ជាពិសេស ច្បាប់ឬវិធាននានា ត្រូវតែមានចែងជាអាទិ៍ ៖

i.អាជ្ញាធររដ្ឋបាលឯករាជ្យ ឬអាជ្ញាធរតុលាការ ត្រូវប្រើយុត្តាធិការក្នុងករណីប្រើប្រាស់កម្លាំងនិងអាវុធរបៀបនេះ។
ii.ក្នុងករណីមានការស្លាប់ និងរងរបួសធ្ងន់ធ្ងរ ឬផលវិបាកធ្ងន់ធ្ងរដទៃទៀត ត្រូវផ្ញើរបាយការណ៍ពិស្តារភ្លាមៗទៅអាជ្ញាធរមានសមត្ថកិច្ច ដែលទទួលខុសត្រូវពិនិត្យមើលផ្នែករដ្ឋបាលនិងការត្រួតពិនិត្យតាមផ្លូវតុលាការ។
iii.អ្នកទាំងឡាយដែលរងការប៉ះពាល់ដោយសារការប្រើកម្លាំងនិងអាវុធ ត្រូវតែមានសិទ្ធិតាមផ្លូវច្បាប់ទាមទារសំណងតាមនីតិវិធីត្រួតពិនិត្យឯករាជ្យមួយទោះធ្វើដោយផ្ទាល់ខ្លួន ឬក៏តាមរយៈតំណាងខាងផ្លូវច្បាប់របស់ខ្លួនក្តី រួមទាំងនីតិវិធី

តាមផ្លូវតុលាការផង។ ក្នុងព្រឹត្តិការណ៍បណ្តាលឲ្យមានការស្លាប់មនុស្សបែប នោះ ត្រូវអនុវត្តចំពោះអាណាព្យាបាលរបស់ខ្លួន។

ឈ. ច្បាប់ឬបទបញ្ញត្តិត្រូវតែចែងពីគោលការណ៍ណែនាំច្បាស់លាស់ ស្តីពីប្រភេទអាវុធដែលអាចប្រើបាន តាមប្រភេទផ្សេងគ្នានៃបុគ្គលិកប្រតិបត្តិច្បាប់នៅក្នុងស្ថានភាពជាក់លាក់មានជាអាទិ៍បាតុកម្មនិងការជួបប្រជុំផ្សេងទៀត។ដោយគោរពតាមគោលការណ៍ជាមូលដ្ឋានរបស់អង្គការសហប្រជាជាតិនេះគេត្រូវតែបញ្ចូលរាយឈ្មោះមធ្យោបាយឲ្យធំទូលាយតាមដែលអាចធ្វើទៅបាននិងតាមទីកន្លែងសមស្របរាយប្រភេទអាវុធនិងគ្រាប់ដែលអនុញ្ញាតឲ្យការប្រើប្រាស់ក្នុងស្ថានភាពផ្សេងគ្នា។ គេត្រូវតែបញ្ចូលអាវុធមិនប្រល័យជីវិតសម្រាប់ប្រើប្រាស់ក្នុងស្ថានភាពសមស្របដោយរឹតបណ្តឹងឡើងជាលំដាប់លើការប្រើមធ្យាបាយ ដែលអាចបណ្តាលឲ្យស្លាប់ ឬរបួសដល់មនុស្ស។ ជាពិសេសច្បាប់ឬបទបញ្ញត្តិនោះ ត្រូវតែមានបញ្ចូល ៖

i. ការណែនាំច្បាស់លាស់អំពីប្រភេទមន្ត្រីអនុវត្តច្បាប់ដែលអាចកាន់សព្វាវុធទូទៅនិងជាពិសេសកាំភ្លើងដៃ។
ii. ការណែនាំច្បាស់លាស់ ដែលរាយពីប្រភេទសព្វាវុធដែលអាចប្រើប្រាស់នៅក្នុងស្ថានភាពពិសេសណាមួយ
iii. ការហាមឃាត់ប្រើប្រាស់សព្វាវុធស្វ័យប្រវត្តិខ្ពស់ក្នុងការរក្សាសណ្តាប់ធ្នាប់បាតុកម្មនិងការជួបប្រជុំផ្សេងទៀត
iv. ការហាមឃាត់ប្រើប្រាស់អាវុធច្នៃប្រឌិត មានជាអាទិ៍ដំបងបារដែកនិងចំពាមនិងសព្វាវុធដែលមិនបម្រើមុខងាររក្សាសណ្តាប់ធ្នាប់ ឬដែលមានឥទ្ធិពលជាប់ជាមួយនាំឲ្យមានគ្រោះថ្នាក់ដែលមិនអាចការពារបាន។
v. ការណែនាំច្បាស់លាស់អំពីការប្រើប្រាស់ប្រភេទផ្សេងគ្នានៃសព្វាវុធមិនប្រល័យជីវិតមនុស្ស។

១៧. កែឬលុបចោលមាត្រា ៦.១០នៃសេចក្តីប្រកាសលេខ០០៦ស្តីពីបទវិន័យរបស់កងកម្លាំងនគរបាលជាតិដើម្បីលុបចោលអំណាចបោសសំអាតរបស់នគរបាលដោយការប្រើអាវុធដើម្បីការពារទ្រព្យសម្បត្តិសាធារណៈ ឬឯកជន។នៅពេលការអនុម័តច្បាប់និងបទបញ្ញត្តិដែលកំណត់នូវក្រមសីលធម៌គ្រប់ជ្រុងជ្រោយស្តីពីការប្រើប្រាស់កម្លាំងដោយមន្ត្រី

ប្រតិបត្តិច្បាប់សេចក្តីយោងទៅគោលការណ៍ណែនាំទាំងនេះគួរត្រូវបានរួមបញ្ចូលនៅក្នុងសេចក្តីប្រកាសលេខ០០៦ដែលជាបទដ្ឋានអំណាចស្តីពីការប្រើប្រាស់កងកម្លាំងនិងអាវុធដោយនគរបាលជាតិ។

១៨. ផ្តល់ការបណ្តុះបណ្តាលដល់បុគ្គលិកប្រតិបត្តិច្បាប់អំពីការគ្រប់គ្រងហ្វូងមនុស្សអហិង្សាការវាយតម្លៃការគំរាមកំហែងនិងអំពីការបន្ថយគ្រោះថ្នាក់នៅក្នុងបរិបទនៃការធ្វើបាតុកម្មនានា។ការបណ្តុះបណ្តាលត្រូវផ្តល់ដល់គ្រប់បុគ្គលិកប្រតិបត្តិច្បាប់អំពីបទដ្ឋានអន្តរជាតិស្តីពីការប្រើប្រាស់កងកម្លាំងនិងអាវុធនិងស្តីពីគោលការណ៍ណែនាំដែលមាននៅក្នុងច្បាប់និងបទបញ្ញត្តិនានានិងក្រមសីលធម៌គ្រប់ជ្រុងជ្រោយស្តីពីការប្រើប្រាស់កងកម្លាំងដោយបុគ្គលិកប្រតិបត្តិច្បាប់ទាំងអស់ ដូចដែលបានរៀបរាប់ខាងលើ។

## ធានាការទទួលខុសត្រូវ<br>ចំពោះការរំលោភសិទ្ធិមនុស្ស

១៩. ធានាថារាល់ករណីសង្ស័យថាជាការរំលោភសិទ្ធិមនុស្សនៅក្នុងបរិបទនៃការជួបប្រជុំជាពិសេសអ្នកដែលពាក់ព័ន្ធនឹងការស្លាប់រងរបួសឬមានគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀតត្រូវតែមានការស៊ើបអង្កេតភ្លាមឯករាជ្យមិនលម្អៀងនិងយ៉ាងហ្មត់ចត់។

២០. ធានាថា ជនទាំងឡាយដែលសង្ស័យថាបានទទួលខុសត្រូវចំពោះការប្រព្រឹត្តបទល្មើសពាក់ព័ន្ធនឹងការរំលោភសិទ្ធិមនុស្សនៅក្នុងបរិបទនៃការប្រជុំត្រូវតែនាំខ្លួនមកកាត់ទោស ស្របតាមនីតិវិធី ដែលមានក្នុងបទដ្ឋានអន្តរជាតិស្តីពីយុត្តិធម៌។ រឿងនេះត្រូវរួមបញ្ចូលទាំងការកាត់ទោសនៃជនទាំងឡាយណាដែលបានចេញបញ្ជាប្រើអំពើហិង្សា និងជនទាំងឡាយដែលធ្វើតាមបទបញ្ជាទាំងនោះ។

២១. ផ្តល់ពត៌មានដល់សាធារណៈជនអំពីការស៊ើបអង្កេតរួមទាំងសំយោគអំពីការស្លាប់នៃបុគ្គលដែលបានបាញ់សម្លាប់នៅថ្ងៃទី១៥ខែកញ្ញាឆ្នាំ២០១៣, ថ្ងៃទី១២ខែវិច្ឆិកាឆ្នាំ២០១៣ និងថ្ងៃទី៣ខែមករាឆ្នាំ២០១៤។

២២. ត្រូវចាប់ផ្តើមការស៊ើបអង្កេតពេញលេញមួយទៅក្នុងការបាត់ខ្លួនដោយបង្ខំនៃក្មេងប្រុស ខឹម សុផាត និងផ្តល់ព័ត៌មានទៅក្រុមគ្រួសាររបស់គាត់ ដូចបានតម្រូវឲ្យធ្វើដូច្នេះ

ដោយអនុសញ្ញាអន្តរជាតិស្តីពីការការពារមនុស្សគ្រប់រូបពីការបាត់ខ្លួនដោយបង្ខំ។

២៣.បង្កើតការស៊ើបអង្កេតមួយដែលឯករាជ្យមិនលំអៀងនិងមានប្រសិទ្ធភាពលើពាក្យបណ្តឹងដែលមានស្រាប់ទាំងអស់ ប្រឆាំងនឹងសន្តិសុខខណ្ឌ រួមទាំងនៅទីកន្លែងដែលធ្វើសកម្មភាពឲ្យមានការរងរបួសធ្ងន់ធ្ងរ។

២៤.អនុម័តច្បាប់បង្កើតប្រព័ន្ធផ្លូវការស្តីពីសំណងរបស់រដ្ឋសម្រាប់ជនរងគ្រោះនៃការរំលោភសិទ្ធិមនុស្ស ស្របទៅតាមបទដ្ឋានអន្តរជាតិនិងធានាថាសិទ្ធិទទួលបានដំណោះស្រាយរបស់ជនរងគ្រោះនៃការរំលោភបំពាន ដែលត្រូវបានគូសបញ្ជាក់នៅក្នុងរបាយការណ៍នេះ នឹងត្រូវបានបំពេញរួមទាំងតាមរយៈវិធានការសងឲ្យដូចដើម សំណងការខូចខាត នីតិសម្បទា ការបំពេញចិត្ត និងការធានាមិនឲ្យប្រព្រឹត្តអំពើច្រំដែល។

២៥.ផ្តល់សច្ចាប័នលើពិធីសារបន្ថែមទីមួយរបស់កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងនយោបាយ ដើម្បីអនុញ្ញាតឱ្យគណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិទទួលនិងពិចារណាលើទំនាក់ទំនងពីបុគ្គលដែលអះអាងថាជាជនរងគ្រោះនៃការរំលោភលើសិទ្ធិណាមួយដែលមានចែងក្នុងកតិកាសញ្ញានេះ។

២៦.បង្កើតស្ថាប័នសិទ្ធិមនុស្សជាតិមួយដោយផ្អែកលើគោលការណ៍ទីក្រុងប៉ារីសដែលជាអង្គការឯករាជ្យមួយរបស់រដ្ឋាភិបាលដែលមានអំណាចទទួលនិងពិចារណាពាក្យបណ្តឹងរំលោភសិទ្ធិមនុស្ស ក្នុងចំណោមភារកិច្ចផ្សេងទៀត។

២៧.បង្កើតអង្គការឯករាជ្យឃ្លាំមើលនគរបាល ដែលដឹកនាំដោយក្រុមស៊ីវិលមួយ និងដែលមានសមត្ថភាពស៊ើបអង្កេតលើការចោទប្រកាន់ពីកំហុសវិជ្ជាជីវៈរួមទាំងការប្រើប្រាស់កម្លាំងជ្រុលហួសហេតុផងដែរ។

២៨.បង្កើតយន្តការបង្ការថ្នាក់ជាតិ ដែលមានឯករាជ្យមានធនធានល្អ ជាតំណាងនិងមានជំនាញវិជ្ជាជីវៈ រួមជាមួយអាជ្ញាធរដើម្បីចុះមើលគ្រប់កន្លែងឃុំឃាំងមនុស្សទាំងអស់ និងជួបមនុស្សដែលគេដកហូតសេរីភាព ធ្វើរបាយការណ៍និងផ្តល់អនុសាសន៍សម្រាប់ការបង្ការអំពើទារុណកម្ម និងការប្រព្រឹត្ត ឬទណ្ឌកម្មដទៃទៀត ដែលឃោរឃៅអមនុស្សធម៌ ឬបន្ទាបបន្ថោក ស្របតាមពិធីសារបន្ថែមនៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម។

២៩.ធានាថាគណៈកម្មាធិការសិទ្ធិមនុស្សរបស់រដ្ឋសភាតាមដានវឌ្ឍនភាពនៃពាក្យបណ្តឹងទាំងអស់ដែលបានដាក់ជូនដោយជនរងគ្រោះនៃការប្រើប្រាស់កម្លាំងដែលមិនចាំបាច់និងជ្រុលហួសប្រមាណ។

# បញ្ឈប់ការយាយីដោយផ្លូវតុលាការ

៣០.អនុវត្តតាមអនុសាសន៍ពិស្តារស្តីពីកំណែទម្រង់ប្រព័ន្ធតុលាការដែលបានស្នើរនៅក្នុងរបាយការណ៍ឆ្នាំ២០១០ របស់អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីស្ថានភាពសិទ្ធិមនុស្សនៅប្រទេសកម្ពុជា។[18] ប្រការនេះត្រូវដាក់បញ្ចូលទាំងការធានាឯករាជ្យភាពរបស់តុលាការនិងស្ថាប័ន នានា ដែលគាំទ្រដល់ការប្រព្រឹត្តទៅនៃតុលាការចៅក្រមមេធាវីនិងបុគ្គលិកច្បាប់។

៣១.ធានាថាគ្មានបុគ្គលណាម្នាក់ ត្រូវបានគេចាប់ខ្លួន ចោទប្រកាន់ នាំខ្លួនទៅកាត់ទោស ឬដាក់ពន្ធនាគារចំពោះការប្រើប្រាស់ដោយសន្តិវិធីនូវសិទ្ធិរបស់ខ្លួនក្នុងសេរីភាពជួបប្រជុំដោយសន្តិវិធី ការចូលរួមសមាគមនិងការបញ្ចេញមតិឡើយ។

៣២.ធានាថាបុគ្គលដែលចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌទាក់ទងទៅនឹងការរៀបចំឬការដឹកនាំប្រជុំត្រូវតែវិនិច្ឆ័យទោសទៅតាមបទល្មើសដែលទទួលស្គាល់ជាអន្តរជាតិតែប៉ុណ្ណោះ និងដោយ សាលាក្តីឯករាជ្យនិងមិនលំអៀង ស្របតាមនីតិវិធី តម្រូវដោយបទដ្ឋានអន្តរជាតិស្តីពីភាពយុត្តិធម៌។

៣៣.ត្រូវចេញគោលការណ៍ណែនាំស្តីពីនីតិវិធីនៃបណ្តឹងព្រហ្មទណ្ឌដោយតុលាការដើម្បីបញ្ចប់ការ ការយាយីតាមផ្លូវតុលាការលើមនុស្សដែលបានចូលរួមរៀបចំការប្រជុំនិងធានាថា ពាក្យបណ្តឹងប្រឆាំងនឹងបុគ្គលិកសន្តិសុខត្រូវធ្វើតាមនីតិវិធីស្របនឹងបទដ្ឋានកម្ពុជានិងអន្តរជាតិ។គោលការណ៍ណែនាំបែបនេះ ត្រូវដាក់បញ្ចូល ៖

ក.ការណែនាំច្បាស់លាស់ស្តីពីបទដ្ឋានជំនុំជំរះក្តីដោយយុត្តិធម៌អន្តរជាតិរួមទាំងសិទ្ធិទទួលសវនាការដោយគ្មានពន្យាពេលហួសហេតុពេក។ការណែនាំបែបនេះគួរតែរំ

[18] អ្នករាយការណ៍ពិសេសស្តីពីរបាយការណ៍កម្ពុជា ខែកញ្ញា ២០១០ (A/HRC/15/46)

ពួកព្រះរាជអាជ្ញាតាមការបង្គាប់ ក្រោមក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដើម្បីផ្តួចផ្តើមនីតិវិធីព្រហ្មទណ្ឌ ឬ "រក្សាទុកសំណុំឯកសារមិនចាត់ការ" ដើម្បីបញ្ចប់ការអនុវត្តការចោទប្រកាន់ព្រហ្មទណ្ឌ ដែលផ្តួចផ្តើមប្រឆាំងនឹងបុគ្គល ដែលមិនត្រូវទម្លាក់បទចោទ ឬមិនធ្វើសវនាកានិងសម្រេចកាត់ក្តី ដោយសាលាក្តីឯករាជ្យ និងមិនលំអៀង។

ខ.ការណែនាំច្បាស់លាស់ អំពីតម្រូវការក្រោមក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា សម្រាប់ការជូនដំណឹងទៅដើមបណ្តឹង "ក្នុងរយៈពេលខ្លីបំផុតដែលអាចធ្វើទៅបាន"និងមិនលើសពីពីរខែបន្ទាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីពាក្យបណ្តឹងព្រហ្មទណ្ឌ អំពីការសម្រេចចិត្តមួយដើម្បី "រក្សាទុកឯកសារមិនចាត់ការ"។

គ.វិធានការវិជ្ជមាន ដើម្បីលើកទឹកចិត្តដល់ជនរងគ្រោះនៃការរំលោភសិទ្ធិមនុស្សនៅកន្លែងប្រជុំដើម្បីដាក់ពាក្យបណ្តឹងព្រហ្មទណ្ឌ។

៣៤.ធានាឱ្យបាននូវការគោរពសិទ្ធិជំនុំជម្រះក្តីដោយយុត្តិធម៌ រួមទាំងអ្នកទាំងឡាយដែលកំពុងតែស្ថិតក្នុងសវនាកាកាត់ទោស ទំនាក់ទំនងទៅនឹងព្រឹត្តិការណ៍ដែលបានពិពណ៌នានៅក្នុងរបាយការណ៍នេះ។

៣៥.ពិនិត្យឡើងវិញនូវការកាត់ទោសនិងការផ្តន្ទាទោសនៅក្នុងករណីដែលជាប់ពាក់ព័ន្ធទាំងអស់ ចាត់ជាមោឃៈនូវការផ្តន្ទាទោសដែលមិនត្រូវបានគាំទ្រដោយច្បាប់ឬដែលគ្មានភស្តុតាងនិងត្រូវដោះលែងជាបន្ទាន់ និងដោយគ្មានលក្ខខណ្ឌអ្វីទាំងអស់នូវអ្នកទាំងឡាយដែលត្រូវបានគេដាក់គុក ដោយសារការប្រើប្រាស់ដោយសន្តិវិធីនូវសិទ្ធិមនុស្សរបស់ពួកគេ។

AMNESTY
INTERNATIONAL

www.amnesty.org